KHMER

# Commonwealth Ombudsman

## ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាពាក់ព័ន្ធនឹងរឿងរ៉ាវសហព័ន្ធ

ភ្នាក់ងារស៊ើបអង្កេតរឿងរ៉ាវសហព័ន្ធគឺជាបុគ្គលឯករាជ ធ្វើការអង្កេតតាមដានបណ្តឹងនានាប្រឆាំងនឹងក្រសួងរដ្ឋាភិបាលសហព័ន្ធ។

### មុខងាររបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាអាចធ្វើការអង្កេតតាមដានបណ្តឹងទាំងឡាយពាក់ព័ន្ធទៅនឹងទីភ្នាក់ងារភាគច្រើននៃរដ្ឋាភិបាលអូស្ត្រាលី ដោយរួមទាំង Centrelink ការិយាល័យពន្ធដារ ទីភ្នាក់ងារផ្គត់ផ្គង់ចិញ្ចឹមកូន ក្រសួងអន្តោប្រវេសន៍ និង ប្រៃសណីយ៍អូស្ត្រាលីជាដើម។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ានឹងធ្វើសេចក្តីសំរេចថាតើទង្វើ ឬក៏សេចក្តីសំរេចទាំងពួងដែលគេអះអាងនោះពិតជាខ្វះភាពត្រឹមត្រូវ, មិនសមហេតុផល, មិនយុត្តិធម៌ ឬក៏មានការប្រកាន់រើសអើងដែរឬទេ។ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាក៏មើលការខុសត្រូវចំពោះការស៊ើបអង្កេតលើការឃឹតឃុំ ឬក៏កង្វះការចាត់សកម្មភាពផ្នែករដ្ឋបាលជាដើម។

យ៉ាងណាមិញ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាមិនអាចស៊ើបអង្កេតបណ្តឹងតវ៉ាពាក់ព័ន្ធនឹងបុគ្គល ឬក្រុមហ៊ុនឯកជនសេចក្តីសំរេចរបស់តុលាការ សកម្មភាពឬក៏សេចក្តីសំរេចរបស់រដ្ឋ ឬក៏សាលាក្រុង មន្ត្រីរដ្ឋាភិបាល ឬក៏សហគ្រិនអាជីវកម្មមួយចំនួនរបស់រដ្ឋាភិបាលបានឡើយ។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាជាជនដែលមិនលំអៀង ហើយមានតួនាទីស្វែងរកលទ្ធផលត្រឹមត្រូវ។

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាធ្វើការដើម្បីកែលំអកិច្ចការរដ្ឋបាលសាធារណៈឲ្យមានលក្ខណៈប្រសើរឡើងដើម្បីទប់រារាំងកុំឲ្យបញ្ហាបែបនេះកើតមានឡើងម្តងហើយម្តងទៀត។

### អំណាចរបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាមានអំណាចធំទូលាយសំរាប់ធ្វើការស៊ើបអង្កេតបណ្តឹងទាំងពួង ដោយរួមទាំងអំណាចចេញបញ្ជាឲ្យភ្នាក់ងារទាំងឡាយប្រគល់ឯកសារ ឬឆ្លើយតបទៅនឹងសំណួរនានា។ បើសិនជាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ារកឃើញកំហុសនៅក្នុងកិច្ចការរដ្ឋបាល ភ្នាក់ងារនេះអាចស្នើសុំឲ្យទីភ្នាក់ងារទទួលខុសត្រូវនោះ កែតម្រូវកំហុសនោះ ឬដោះស្រាយបញ្ហានោះ។ ឧទាហរណ៍ ភ្នាក់ងារនេះអាចស្នើសុំឲ្យទីភ្នាក់ងារទទួលខុសត្រូវនោះផ្តល់ការពន្យល់ ឬសុំការអភ័យទោស កែតម្រូវសេចក្តីសំរេចណាមួយ បោះបង់ចោលបំណុល ឬក៏សងជំងឺចិត្តជាដើម។

## របៀបធ្វើបណ្តឹងតវ៉ា

មុននឹងទាក់ទងការិយាល័យរបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា លោកអ្នកគប្បីព្យាយាមដោះស្រាយបញ្ហា ដោយការទាក់ទងទីភ្នាក់ងាររដ្ឋបាល ដែលលោកអ្នកមានការមិនពេញចិត្តនោះ ដោយលោកអ្នកអាចទាក់ទងផ្ទាល់ទៅខាងផ្នែកសេវាទទួលបណ្តឹងរបស់ទីភ្នាក់ងារនោះ បើសិនជាមាន។ បើសិនជាលោកអ្នកធ្វើបណ្តឹងអំពីសេចក្តីសំរេចចិត្តណាមួយ លោកអ្នកគប្បីស្វែងសុំឲ្យមានការពិនិត្យសេចក្តីសំរេចចិត្តនោះសាឡើងវិញ បើអាចធ្វើទៅបាន។ ការិយាល័យភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា មាននៅក្នុងរដ្ឋធានី នៃដែនដី និង រដ្ឋទាំងអស់។ លោកអ្នកអាចធ្វើបណ្តឹងដោយ ចូលទៅជួបផ្ទាល់ ឬ ដោយទូរស័ព្ទ លិខិត ទូរសារ ឬក៏អ៊ីមែល។ លោកអ្នកក៏អាចទូរស័ព្ទទៅភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា តាមរយៈលេខ 1300 362 072 ដោយអស់ថ្លៃស្មើនឹងការប្រើ ទូរស័ព្ទក្នុងតំបន់។ លោកអ្នកក៏អាចផ្តល់សិទ្ធិអំណាចទៅជនណាម្នាក់, មិត្តភក្តិ, សាច់ញាតិ ឬក៏ភ្នាក់ងារសហគមន៍ឲ្យធ្វើបណ្តឹងជំនួសឲ្យលោកអ្នកបានដែរ។ ប្រជាជនដែលមាន សាវតារមិននិយាយភាសាអង់គ្លេស ហើយមានបំណងទាក់ទងការិយាល័យភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ានោះ គេអាចធ្វើកិច្ចការនេះបានតាមរយៈសេវាបកប្រែភាសា Translation and Interpreting Service (TIS) ទូរស័ព្ទលេខ 131 450 ឬក៏ធ្វើបណ្តឹងរបស់ខ្លួនតាមលិខិតដោយសរសេរជាភាសារបស់ខ្លួន។

## ភាពលាក់ការសម្ងាត់ និង ការផ្តល់សេវាដោយឥតបង់ថ្លៃ

ការស៊ើបអង្កេតលើបណ្តឹងគឺប្រព្រឹត្តទៅដោយលាក់ការសម្ងាត់ ហើយសេវាគឺផ្តល់ជូនដោយឥតគិតថ្លៃឡើយ។

# លោកអ្នកមានសិទ្ធិធ្វើបណ្តឹងតវ៉ា

ព័ត៌មាននេះគឺគ្រាន់តែជាការណែនាំប៉ុណ្ណោះ។ ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទងភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាសហព័ន្ធ។

## ទាក់ទងយើងខ្ញុំ

ដោយចំណាយត្រឹមតែថ្លៃទូរស័ព្ទក្នុងតំបន់ លោកអ្នកអាចទាក់ទងការិយាល័យភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាសហព័ន្ធដែលនៅជិតលោកអ្នកជាងគេ ដោយទូរស័ព្ទទៅបណ្តាញជាតិសំរាប់ការធ្វើបណ្តឹង (National Complaints Line ) 1300 362 072 (កំណត់ចំណាំ : ការប្រើ ទូរស័ព្ទចល័តនឹងត្រូវបង់ថ្លៃតាមអត្រាទូរស័ព្ទចល័ត)

អ៊ីមែល: ombudsman@ombudsman.gov.au

វិបសាយ: www.ombudsman.gov.au

## ការិយាល័យរបស់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

### ADELAIDE
ទូរស័ព្ទ 1300 362 072
ទូរសារ 08 8226 8618
Level 5, 50 Grenfell Street
Adelaide SA 5000

### BRISBANE
ទូរស័ព្ទ 1300 362 072
ទូរសារ 07 3229 4010
Level 17, 53 Albert Street
Brisbane QLD 4000

### CANBERRA & NATIONAL OFFICE
ទូរស័ព្ទ 1300 362 072
ទូរសារ 02 6249 7829
GPO Box 442
Canberra ACT 2601

Ground Floor, 1 Farrell Place
Canberra City ACT 2600

### DARWIN
ទូរស័ព្ទ 1300 362 072
ទូរសារ 08 8941 5400
GPO BOX 1344, Darwin NT 0801

Level 12, NT House
Cnr Bennett & Mitchell Streets
Darwin NT 0801

### HOBART
ទូរស័ព្ទ 1300 362 072
ទូរសារ 03 6233 8966
GPO Box 960
Hobart Tas 7001

Ground Floor
99 Bathurst Street
Hobart TAS 7000

### MELBOURNE
ទូរស័ព្ទ 1300 362 072
ទូរសារ 03 9867 3750
Level 1
441 St Kilda Road
Melbourne VIC 3004

### PERTH
ទូរស័ព្ទ 1300 362 072
ទូរសារ 08 9221 4381
PO Box Z5386
St Georges Terrace
Perth WA 6831

Level 12, St Martin's Tower
44 St Georges Terrace
Perth WA 6000

### SYDNEY
ទូរស័ព្ទ 1300 362 072
ទូរសារ 02 9211 4402
PO Box K825
Haymarket NSW 1240

Level 7, North Wing
Sydney Central
477 Pitt Street
Sydney NSW 2000

## មានការផ្តល់សេវាជួយលោកអ្នកដើម្បីធ្វើបណ្តឹងតវ៉ា

បើលោកអ្នកមិនអាចនិយាយភាសាអង់គ្លេសបានទេនោះ យើងខ្ញុំអាចជួយលោកអ្នកតាមរយៈសេវាអ្នកបកប្រែភាសា Translating and Interpreting Service (TIS) លេខ 131 450. បើលោកអ្នកមានពិការភាពភ្នែក, សោតវិញ្ញាណ ឬក៏ការនិយាយ យើងមាន TTY Service ជូនលោកអ្នកតាមរយៈ National Relay Service